# សន្ទស្សន៍ភាពធន់របស់ស្ត្រីនៅកម្ពុជា

***ភាពងាយរងគ្រោះកាន់តែមានសភាពធ្ងន់ធ្ងរ និងប៉ះពាល់ផ្ទាល់ដល់ជីវភាពប្រចាំថ្ងៃ៖***
*ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅលេខរៀងទី១៩ក្នុងចំណោម១៨១ប្រទេសដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ១៩៩៣-២០១៧។[១] ការខូចខាត និងបាត់បង់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១៥ ត្រូវបានប៉ាន់ប្រមាណថាមាន១,៥ពាន់លានដុល្លារអាមេរិក។[២] ឥទ្ធិពលបាតុភូតអេលនីញូបានប៉ះពាល់ដល់កំរិតគ្រួសារ ដែលក្នុងនោះប្រជាជន ១៣% ត្រូវខ្ចីបំណុលបន្ថែម ប្រហែល ១.២៨២ដុល្លារក្នុងមួយខ្នងផ្ទះ។[៣] ជាងនេះទៅទៀត មានការព្យាករណ៍ថា ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនឹងបន្តកើនឡើងជានិច្ច និងអាចធ្វើឲ្យប្រជាជនកម្ពុជានៅជនបទ៦១% នឹងក្លាយជាជនរងគ្រោះ ជាពិសេស កសិករខ្នាតតូចប្រហែលជាង៧លាននាក់ និងកម្មករសំណង់ជាង២៤ម៉ឺននាក់។[២] រាជរដ្ឋាភិបាលទទួលស្គាល់ថាប្រជាជនក្រីក្រនៅជនបទ និងភាគច្រើនស្ត្រីជាអ្នកងាយរងគ្រោះជាងគេដោយសារជីវភាពពួកគេពឹងផ្អែកខ្ពស់លើវិស័យកសិកម្ម និងធនធានធម្មជាតិ។*

***សន្ទស្សន៍ភាពធន់របស់ស្ត្រីនៅកម្ពុជា សិក្សាពីតម្រូវការនានាដែលត្រូវធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរ ជាវិជ្ជមាន ដើម្បីកសាងភាពធន់របស់ស្ត្រី និងសហគមន៍ នៅថ្នាក់មូលដ្ឋាន លើផ្នែកសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សង្គម និងស្ថាប័ន ដោយប្រៀបធៀបកម្រិតភាពធន់រវាងស្ត្រី និងបុរសនៅកម្រិតមូលដ្ឋាន ។***

*សន្ទស្សន៍នេះ ត្រូវបានបង្កើតឡើងស្របតាមសន្ទស្សន៍ភាពធន់របស់ ស្ត្រីនៅអាស៊ីខាងត្បូង។ វាត្រូវបានរៀបចំដោយឈរលើវិធីសាស្ត្រយកសិទ្ធិមនុស្ស ជាមូលដ្ឋាន និងក្របខណ្ឌការងារ កសាងភាពធន់របស់អង្គការ អាកសិនអេត អន្តរជាតិ។*



**សេដ្ឋកិច្ច**
វាស់វែងពីប្រាក់ចំណូល ការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិជាប្រភពចំណូល ការទទួលបានកម្ចី និងទីផ្សារ។

**ហេដ្ឋារចនាសម្ព័ន្ធ**
វាស់វែងពីហេដ្ឋារចនាសម្ព័ន្ធនិងទីតាំងរស់នៅ ការទទួលបានថាមពល ទឹកស្អាត និងអនាម័យ ធាតុចូលសម្រាប់របរចិញ្ចឹមជីវិត បច្ចេកវិទ្យាទំនាក់ទំនង ប្រព័ន្ធប្រកាសឲ្យដឹងមុន និងប្រព័ន្ធការពារឬកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ។

**សង្គម**
វាស់វែងពីការទទួលការអប់រំ ព័ត៌មាន ការថែទាំសុខភាព សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការបំលាស់ទីក្នុងសង្គម ចំណាកស្រុក សន្តិសុខសង្គម សាសនា អំពើហិង្សាផ្អែកយេនឌ័រ និងការត្រៀមបង្ការ។

**ស្ថាប័ន**
វាស់វែងពី ការចូលរួមនិងដឹកនាំក្នុងដំណើរការសម្រេចចិត្ត និងការឆ្លើយតបដោយស្ថាប័នសាធារណៈ ផែនការនិងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ និង តួនាទីប្រព័ន្ធសារព័ត៌មាន។

## វិធីសាស្ត្រស្រាវជ្រាវ

- **សំយោគបណ្ណាល័យសាស្ត្រ** (ឯកសារជាតិ និង អន្តរជាតិ)
- **ស្ទង់មតិតាមគ្រួសារ** (៦៩៦ គ្រួសារ, កម្រិតទុកចិត្ត ៩៦%, លម្អៀង .០៤)
- **ក្រុមពិភាក្សា**(១៥ ក្រុម)
- **សម្ភាសន៍ជនបង្គោល** (៤៣ រូប)
- **សម្ភាសន៍ស៊ីជម្រៅ** (១២ រូប)




■ ពិន្ទុប្រុស ■ ពិន្ទុស្រី

| | សន្ទស្សន៍ភាពធន់ (ប្រុស) | សន្ទស្សន៍ភាពធន់ (ស្រី) | សេដ្ឋកិច្ច (ប្រុស) | សេដ្ឋកិច្ច (ស្រី) | ហេដ្ឋារចនាសម្ព័ន (ប្រុស) | ហេដ្ឋារចនាសម្ព័ន (ស្រី) | សង្គម (ប្រុស) | សង្គម (ស្រី) | ស្ថាប័ន (ប្រុស) | ស្ថាប័ន (ស្រី) |
|---|---|---|---|---|---|---|---|---|---|---|
| ភាពធន់រួម | .59 | .56 | .61 | .59 | .58 | .56 | .57 | .54 | .61 | .56 |
| ប្រជុំជន | .60 | .58 | .63 | .62 | .62 | .59 | .58 | .56 | .59 | .56 |
| ជនបទ | .59 | .56 | .60 | .58 | .57 | .55 | .57 | .53 | .62 | .56 |

| | សន្ទស្សន៍ភាពធន់ (ប្រុស) | សន្ទស្សន៍ភាពធន់ (ស្រី) | សេដ្ឋកិច្ច (ប្រុស) | សេដ្ឋកិច្ច (ស្រី) | ហេដ្ឋារចនាសម្ព័ន (ប្រុស) | ហេដ្ឋារចនាសម្ព័ន (ស្រី) | សង្គម (ប្រុស) | សង្គម (ស្រី) | ស្ថាប័ន (ប្រុស) | ស្ថាប័ន (ស្រី) |
|---|---|---|---|---|---|---|---|---|---|---|
| រាជធានីភ្នំពេញ | .56 | .56 | .59 | .60 | .58 | .62 | .58 | .54 | .49 | .48 |
| ឆ្នេរ | .62 | .59 | .65 | .65 | .60 | .56 | .57 | .54 | .67 | .59 |
| ទំនាប | .60 | .57 | .62 | .60 | .60 | .56 | .57 | .54 | .60 | .57 |
| ទន្លេសាប | .57 | .55 | .57 | .56 | .57 | .56 | .57 | .55 | .57 | .52 |
| ខ្ពង់រាប | .60 | .55 | .59 | .57 | .56 | .53 | .58 | .53 | .66 | .59 |

*ចំណាំ: 0,00 = ពិន្ទុទាបបំផុត 1,00 = ពិន្ទុខ្ពស់បំផុត*

១. សន្ទស្សន៍ហានិភ័យអាកាសធាតុពិភពលោក ២០១៩ ២. ADB ក្នុងខ្មែរថាមស៍ ៣.WFP ក្នុង ភ្នំពេញប៉ុស្តិ៍ ៤. ODC, 2016

## ភាពធន់ផ្នែកសេដ្ឋកិច្ច

ស្ត្រីកម្ពុជាភាគច្រើនកំពុងស្ថិតក្នុងបន្ទាត់នៃភាពងាយរងគ្រោះ។ ខណៈដែលបុរសមានភាពធន់សេដ្ឋកិច្ចក្នុងសន្ទស្សន៍០,៦១ ស្ត្រីមានត្រឹមតែ០,៥៩ប៉ុណ្ណោះ។ ការសិក្សានេះរកឃើញថាស្ត្រីមានតួនាទីស្ទើរស្មើគ្នាជាមួយបុរសក្នុងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន ប៉ុន្តែចំណូលរបស់ពួកគេ មិនមានស្ថេរភាព និងសមរម្យអាចកសាងភាពធន់បានឡើយ។ សន្ទស្សន៍ចំណូលគ្រួសារមានត្រឹមតែ ០,៣៥ ប៉ុណ្ណោះ។ ស្ត្រីហាក់មានលទ្ធភាពគួរសមក្នុងការទទួលបាននូវកម្ចីផ្លូវការ/មិនផ្លូវការ (០,៦១)។ ទោះជាលទ្ធភាពទៅទីផ្សារ បានខ្ពស់ ស្ត្រីនៅតែមានលទ្ធភាពតិចជាងបុរស។ ការថយចុះជាលំដាប់នូវលទ្ធភាពអាស្រ័យផលពីធនធានធម្មជាតិ ដែលជាប្រភពនៃជីវភាពប្រកបដោយនិរន្តរភាព កាន់តែជាឧបសគ្គខ្លាំងឡើងសម្រាប់ប្រជាជននៅជនបទ ក្នុងការកសាងភាពធន់នឹងហានិភ័យគ្រោះមហន្តរាយ និងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ និងវិបត្តសេដ្ឋកិច្ច។




## ភាពធន់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ភាពធន់របស់ស្ត្រី និងបុរសកម្ពុជាក្នុងកម្រិត ០,៥៦ និង០,៥៨ (តាមលំដាប់)។ លទ្ធភាពទទួលបានថាមពលក្នុងតម្លៃសមរម្យសម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យមានកម្រិតខ្ពស់។ ប៉ុន្តែកត្តាប្រឈមចម្បងបំផុតក្នុងការកសាងភាពធន់រួមមានកង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្តការពារមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិ លទ្ធភាពទទួលបានជម្រក/ទីសុវត្ថិភាព ប្រព័ន្ធប្រកាសឲ្យដឹងមុនដែលមានប្រសិទ្ធិភាព លទ្ធភាពទទួលបានធាតុចូល និងសម្ភារៈសំរាប់ជីវភាព និងលទ្ធភាពទទួលបានលំនៅដ្ឋានដែលមានភាពធន់។ លទ្ធភាពទទួលបានមធ្យោបាយធ្វើដំណើរ និងប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនង នៅមានកម្រិតទាបនៅឡើយ។







## ភាពធន់ផ្នែកសង្គម

ភាពធន់របស់ស្ត្រីនៅកម្ពុជាផ្នែកសង្គមគឺ០,៥៤ចំណែកបុរសគឺ០,៥៧។ លទ្ធភាពទទួលបានសេវាសុខភាពមូលដ្ឋានមានពិន្ទុខ្ពស់ និងស្មើគ្នារវាងបុរស និងស្ត្រី។ សន្តិសុខស្បៀងនិងអាហាររូបត្ថម្ភ មានកម្រិតខ្ពស់មធ្យម។ សន្ទស្សន៍នេះបង្ហាញថា បុរសមានភាពភ័យខ្លាច និងបានឃើញមានការកើនឡើងអំពើហិង្សាផ្នែកយេនឌ័រក្នុងអំឡុង និងក្រោយពេលគ្រោះមហន្តរាយតិចជាងស្ត្រី។ អំពើហិង្សាផ្នែកយេនឌ័រមានពិន្ទុ ០,៦៥ សម្រាប់ស្ត្រី និង០,៧៤ សម្រាប់បុរស។ លទ្ធភាពទទួលបានការអប់រំក្នុង និងក្រៅប្រព័ន្ធ ចំណាកស្រុក និងការត្រៀមបង្ការមានកម្រិតទាប។ លទ្ធភាពទទួលបានសន្តិសុខ និងការគាំពារសង្គម និងការគាំទ្រពីក្រុមសាសនា សុទ្ធតែជាកត្តាដែលត្រូវយក ចិត្តទុកដាក់ និងចាត់វិធានការដើម្បីពង្រឹងភាពធន់របស់ប្រជាជនកម្ពុជា។




## ភាពធន់ផ្នែកស្ថាប័ន

សន្ទស្សន៍ភាពធន់ផ្នែកស្ថាប័នគឺ០,៥៦ សម្រាប់ស្ត្រី និង០,៦១ សម្រាប់បុរស។ ស្ត្រីមានការចូលរួមធ្វើសេចក្តីសម្រេចចិត្តតិចជាងបុរស។ សន្ទស្សន៍នេះគឺផ្អែកលើលទ្ធភាពក្នុងការធ្វើការសម្រេចចិត្ត សមភាពអំណាច ចំណេះដឹងអំពីផែនការគ្រប់គ្រងគ្រោះមហន្តរាយ លទ្ធភាពទទួលបានជំនួយមនុស្សធម៌ ការគាំទ្រដោយអភិបាលកិច្ច និងតួនាទីសារព័ត៌មាន។ លទ្ធភាពទទួលបានជំនួយមនុស្សធម៌ ក្នុងអំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយមានកម្រិតទាប។ មានប្រជាជនមូលដ្ឋានតិចតួចដឹងអំពីផែនការគ្រប់គ្រងគ្រោះមហន្តរាយ។ តួនាទីគាំទ្ររបស់សារព័ត៌មាននៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុក៏នៅមានកម្រិតដែរ។

actionaid




## សេដ្ឋកិច្ច

| | | | | |
|---|---|---|---|---|
| 29% | ចំណូលតិចជាង $១.៩០ក្នុង១ថ្ងៃ | 43% | 36% | ចំណូលគ្រួសារប្រចាំខែតិចជាង $២២០ |
| 68% | ចាត់ចែងចំណូលដែលខ្លួនរកបាន | 83% | 29% | គ្មានប្រាក់ចំណូលទៀងទាត់លើសពី៦ខែ |
| 60% | ចាត់ចែងចំណូលក្នុងគ្រួសារ | 77% | 57% | លំបាកទាញយកផលពីធនធានធម្មជាតិ |
| 74% | ម្ចាស់កម្មសិទ្ធិដីដែលកំពុងរស់នៅ | 72% | 57% | យល់ថាបរិមាណធនធានធម្មជាតិទ្រទ្រង់ជីវភាពថយចុះ |
| | | | 56% | យល់ថាគុណភាពធនធានធម្មជាតិទ្រទ្រង់ជីវភាពថយចុះ |

## ហេដ្ឋារចនាសម្ព័ន្ធ

| | | | | |
|---|---|---|---|---|
| 87% | ប្រើទូរស័ព្ទ | 85% | 40% | យល់ថាផ្ទះគ្មានសុវត្ថិភាព |
| 53% | ប្រើអ៊ីនធើណិត | 47% | 29% | យល់ថាផ្ទះមិនស្ថិតនៅក្នុងទីតាំងសុវត្ថិភាព |
| 35% | ស្តាប់វិទ្យុ | 26% | 41% | ប្រាប់ថាផ្ទះខ្លួនងាយរងគ្រោះដោយគ្រោះមហន្តរាយ |
| 74% | មើលទូរទស្សន៍ | 70% | 7% | ប្រាប់ថាផ្ទះខ្លួនស្ថិតនៅទីតាំងមិនស្របច្បាប់ |
| 42% | មិនបានដឹងដំណឹងព័ត៌មានគ្រោះមហន្តរាយ | 49% | 20% | មិនអាចធ្វើដំណើរចេញពីភូមិគ្រប់ពេល១ឆ្នាំទេ |
| 72% | មិនបានដឹងពីទីសុវត្ថិភាព | 77% | 16% | មិនមានទឹកស្អាតប្រើប្រាស់ក្នុងផ្ទះ |
| | | | 14% | ត្រូវធ្វើដំណើរឆ្ងាយជាង៥០០ម៉ែត្រដើម្បីដងទឹក |
| | | | 17% | មិនមានបង្គន់អនាម័យប្រើប្រាស់ |
| | | | 70% | ប្រាប់ថាគ្មានហេដ្ឋារចនាសម្ព័ន្ធរូបវន្តការពារគ្រោះធម្មជាតិ |

## សង្គម

| | | | | |
|---|---|---|---|---|
| 12% | មិនបានទៅសាលារៀន | 25% | 18% | ប្រាប់ថាកុមារបានរៀនពីគ្រោះមហន្តរាយនៅសាលា |
| 76% | អាចអាន និងសរសេរ | 59% | 45% | ប្រើចំណេះដឹងបែបបុរាណឬតាមតំបន់ សម្រាប់ត្រៀមបង្ការ |
| 88% | មើល/ស្តាប់ព័ត៌មានក្នុងស្រុក | 75% | 15% | មិនមានអាហារគ្រប់គ្រាន់ពេញមួយឆ្នាំ |
| 27% | មានធានារ៉ាប់រងសុខភាព | 22% | 81% | ទទួលទានរបបអាហារមានតុល្យភាព (បីក្រុម) |
| 56% | ត្រូវសុំអនុញ្ញាតពីអ្នកផ្ទះមុនចេញពីភូមិ | 63% | 29% | សមាជិកក្នុងផ្ទះត្រូវធ្វើចំណាកស្រុកទៅធ្វើការ |
| 36% | ពេលចេញក្រៅភូមិ ត្រូវការអ្នកទៅជាមួយ | 62% | 21% | ក្រុមសាសនាផ្តល់ជំនួយពេលមានគ្រោះមហន្តរាយ |
| 28% | មានអារម្មណ៍គ្មានសុវត្ថិភាពធ្វើដំណើរក្រៅភូមិ | 31% | 54% | រាយការណ៍ថាអំពើហិង្សានៅតែជាបញ្ហានៅក្នុងភូមិ |
| 17% | ភ័យខ្លាចពីការរំលោភ ឬការបៀតបៀនផ្លូវភេទ | 59% | 13% | មានលទ្ធភាពទទួលបានសំណាញ់សុវត្ថិភាពសង្គម |
| 22% | អំពើហិង្សាយេនឌ័រមានការកើនឡើងនៅកំឡុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ | 28% | | |

## ស្ថាប័ន

| | | | | |
|---|---|---|---|---|
| 67% | ចូលរួមសម្រេចចិត្តក្នុងសហគមន៍ | 54% | 30% | ទទួលបានជំនួយពេលគ្រោះមហន្តរាយ |
| 71% | មានឱកាសដឹកនាំស្មើគ្នា | 57% | 95% | បានទៅបោះឆ្នោតតាមការជ្រើសរើសរបស់ខ្លួន |
| 59% | មិនដឹងថាមានយន្តការ គ.គ.ម | 67% | 31% | យល់ថាសារព័ត៌មានបានរាយការណ៍បានគ្រប់គ្រាន់ |
| 67% | មិនដឹងថាមានផែនការ គ.គ.ម ថ្នាក់ខេត្ត | 75% | 38% | យល់ថាសារព័ត៌មានអាចជួយទាមទារតម្រូវការ |
| 57% | មិនដឹងថាមានផែនការគ.គ.ម.ថ្នាក់ឃុំសង្កាត់ | 65% | 81% | មិនធ្លាប់តម្រូវឲ្យបង់ប្រាក់លើសកំណត់ទៅមន្ត្រីសាធារណៈ |

គ.គ.ម =គ្រប់គ្រងគ្រោះមហន្តរាយ

actionaid

# អនុសាសន៍

ដើម្បីកសាងភាពធន់ថ្នាក់មូលដ្ឋានសម្រាប់ស្ត្រី និងបុរសនៅកម្ពុជា សន្ទស្សន៍ភាពធន់របស់ស្ត្រីនៅកម្ពុជា ផ្តល់អនុសាសន៍ខាងក្រោម ៖

### ១. វិនិយោគលើការកសាងភាពធន់នៅតាមមូលដ្ឋាន៖

ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសរដ្ឋាភិបាល គួរផ្តល់ធនធាន ក្នុងការកសាងភាពធន់នៅតាមសហគមន៍ និងសេដ្ឋកិច្ចដែលមាននិរន្តរភាពសម្រាប់កសិករ និងប្រជានេសាទងាយរងគ្រោះ។ ការកសាងសេដ្ឋកិច្ចដែលពឹងផ្អែកលើខ្លួនឯងនៅថ្នាក់មូលដ្ឋានទាមទារឲ្យមានការវិនិយោគដើម្បីការពារ អភិរក្ស និងការបង្កើតឡើងវិញនូវធនធានធម្មជាតិរួមមានដីបង្កបង្កើនផល ធនធានជលផល និងព្រៃឈើ ដើម្បីលើកកម្ពស់សុវត្ថិភាពស្បៀង ការបង្កើតប្រាក់ចំណូលដែលមាននិរន្តរភាព។ ការអភិវឌ្ឍបៃតង ត្រូវផ្តល់អាទិភាពលើគម្រោងអភិវឌ្ឍន៍ខ្នាតធំ។ ការវិនិយោគនេះអាចលើកកម្ពស់ជីវភាពដែលមាននិរន្តរភាព ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

### ២. វិនិយោគលើការកសាងចំណេះដឹងស្ថាប័ន៖

- កសាងសមត្ថភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ និងរចនាសម្ព័ន្ធបន្សុំានឹងការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់ការបង្កើតនិងអនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ ការផ្តល់ជំនួយមនុស្សធម៌ សេវាសាធារណៈក្នុងវិស័យកសិកម្មនិរន្តរភាព និងការគ្រប់គ្រងធនធានធម្មជាតិ ដោយរួមទាំងការផ្តល់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- សហការជាមួយសង្គមស៊ីវិល ពង្រឹងចំណេះដឹង និងសមត្ថភាពធន់របស់ក្រុមងាយរងគ្រោះបំផុតនៅថ្នាក់មូលដ្ឋាន។

### ៣. វិនិយោគលើការផ្លាស់ប្រែស្ថាប័ន៖

- ធានាសមភាពស្ត្រី និងបុរសក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងការចូលរួម និងដឹកនាំរបស់ស្ត្រីប្រកបដោយអត្ថន័យក្នុងសកម្មភាពនានា។ ឧទាហរណ៍ កំណត់កូតាស្ត្រីក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ។
- ដៃគូរអភិវឌ្ឍន៍ និងរដ្ឋាភិបាលគួរផ្តល់អាទិភាពលើការបង្កើត និងផ្តល់ធនធានដល់ផែនការគ្រប់គ្រងគ្រោះមហន្តរាយ និងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ នៅថ្នាក់ឃុំ/សង្កាត់ និងថ្នាក់ក្រោមជាតិ។
- សង្គមស៊ីវិលគួរផ្តោតធនធានដែលមានកម្រិតរបស់ខ្លួនលើការកសាងអ្នកដឹកនាំស្ត្រី នៅថ្នាក់មូលដ្ឋាន និងក្រោមជាតិ និងសម្របសម្រួលឲ្យពួកគេអាចចូលរួមក្នុងដំណើរការកសាងផែនការ និងបែងចែកធនធានពីមូលដ្ឋានដល់ថ្នាក់ជាតិ។

### ៤. ពង្រឹងអភិបាលកិច្ចស្ថាប័ន៖

- ផ្តល់ឱកាសដល់ស្ត្រីក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងការកសាងផែនការការបែងចែកធនធាន និងការកសាងគោលនយោបាយ ដោយចាប់ផ្តើមពីដំណើរការកសាងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំសង្កាត់។
- រដ្ឋាភិបាលគួរវិនិយោគក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ នៅថ្នាក់មូលដ្ឋាន។ ហេដ្ឋារចនាសម្ព័ន្ធនេះនឹងលើកកម្ពស់សមត្ថភាពភាគីពាក់ព័ន្ធនៅមូលដ្ឋានក្នុងការត្រៀមបង្ការ ឆ្លើយតប និងការបន្សុំាខ្លួន។
- ប្រព័ន្ធប្រកាសឲ្យដឹងមុនដែលមានស្រាប់គួរត្រូវពង្រីកទីតាំងគ្រប់ដណ្តប់ និងផ្តោតលើពហុមុខសញ្ញាគ្រោះមហន្តរាយ និងត្រូវធានាថាវាអាចផ្តល់ព័ត៌មានដល់ក្រុមងាយរងគ្រោះបំផុត។
- ដៃគូរអភិវឌ្ឍន៍ និងរដ្ឋាភិបាលត្រូវទទួលស្គាល់ថាកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងភាពធនរបស់ពួកគេត្រូវឈរលើគោលការណ៍សិទ្ធិមនុស្ស និងមិនមែនជាការផ្តល់ជំនួយមនុស្សធម៌ឡើយ។ ការទទួលស្គាល់នេះអាចធ្វើបានតាមរយៈការយកចិត្តទុកដាក់លើការលើកកម្ពស់ការយល់ដឹង ការពង្រឹងសិទ្ធិអំណាចស្ត្រី និងបុរសឲ្យចេះទាមទារសិទ្ធិ និងឲ្យមន្ត្រីរាជការផ្តល់សេវាឲ្យកាន់តែមានការទទួលខុសត្រូវខ្ពស់បន្ថែមទៀត និងឆ្លើយតបនឹងតម្រូវការស្ត្រី និងបុរសក្នុងការទទួលបានសេវាសាធារណៈក្នុងវិស័យកសិកម្មដែលមាននិរន្តភាព និងការគ្រប់គ្រងធនធានធម្មជាតិ ការគាំពារសង្គម និងការបន្សុំានឹងការប្រែប្រួលអាកាសធាតុ។

**ឧបត្ថម្ភថវិកាដោយ៖**
ជំនួយបរិស្ថានពិភពលោក/កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិតាមរយៈ
គម្រោងពង្រឹងព័ត៌មានអាកាសធាតុ និងប្រព័ន្ធប្រកាសឲ្យដឹងមុន

Empowered lives.
Resilient nations.

**សហការណ៍ឧបត្ថម្ភថវិកាដោយ៖**
ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និង
ផ្តល់ភាពអង់អាចដល់ស្ត្រីតាមរយៈគម្រោង
បង្កើនភាពអង់អាចដល់ស្ត្រី ដើម្បីសង្គមដែលធន់នឹងការប្រែប្រួលអាកាសធាតុ

ΣmPower
ស្ត្រីដើម្បីសង្គមដែលធន់នឹងការប្រែប្រួលអាកាសធាតុ

**សម្រាប់ព័ត៌មាន និង ទិន្នន័យបន្ថែមពី**
**សន្ទស្សន៍ភាពធន់របស់ស្ត្រីនៅកម្ពុជា**


អង្គការ អាកសិនអេត កម្ពុជា
ផ្ទះលេខ ៣៣ ផ្លូវលេខ ៧១, សង្កាត់ទន្លេបាសាក់,
ខណ្ឌចំការមន, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា
លេខទូរស័ព្ទ: ០២៣ ២១១ ៤៦២, ០២៣ ២១១ ៤៦២,
អ៊ីម៉ែល: E-mail.Cambodia@ActionAid.org


Follow us on:
www.actionaid.org
/actionaidcambodia
@actionaidcambodia


© ActionAid Cambodia 2019

## ឧបសម្ព័នទី ១. កម្រងសំណួរស្ទង់មតិ

**ការណែនាំ**

ការណែនាំខ្លួនខ្ញុំឈ្មោះ......................ជាអ្នកប្រមូលទិន្នន័យអោយអង្គការអោកសិកអេត ដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ។ ពួកយើងកំពុងធ្វើការសិក្សាស្រាវជ្រាវពីបទពិសោធន៍របស់ប្រជាជនដែលជួបប្រទះគ្រោះមហន្តរាយនៅក្នុងស្រុក.....។ គោលបំណងនៃការសិក្សានេះ គឺវាស់វែង និងប្រៀបធៀបពីកម្រិតភាពធនរបស់ស្ត្រី និងបុរសទៅនឹងហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។ ចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក នឹងត្រូវបានរក្សាការសំងាត់ជូនហើយប្រសិនបើអ្នកមាន ចម្ងល់ ឬសំណួរអ្វី អាចសួរខ្ញុំបាន ឬទំនាក់ទំនងទៅអ្នកគ្រប់គ្រងការស្រាវជ្រាវនេះ តាមរយៈលេខទូរស័ព្ទ 086339967។

| | |
|---|---|
| លេខកម្រងសំណួរ | |
| កាលបរិច្ឆេទសម្ភាសន៍ | |
| ម៉ោងសម្ភាសន៍ | |
| ខេត្ត | |
| ស្រុក/ខណ្ឌ/ក្រុង | |
| ឃុំ/សង្កាត់ | |
| ភូមិ | |
| លេខសំគាល់ និងឈ្មោះរបស់អ្នកសម្ភាសន៍ | |
| លេខសំគាល់ និងឈ្មោះរបស់អ្នកមេដឹកនាំក្រុម | |

**ផ្នែក - ទូទៅ**

| | **សំនួរ** | **ជម្រើសចម្លើយ/កូដ** |
|---|---|---|
| 1 | ភេទរបស់អ្នកតបសម្ភាសន៍ | □ ស្រី=0<br>□ ប្រុស=1 |
| 2 | អាយុ | ចំនួន________ ឆ្នាំ |
| 3 | ស្ថានភាពអាពាហ៍ពិពាហ៍ | □ នៅលីវ = 0<br>□ រៀបការ = 1<br>□ លែងលះ = 2<br>□ មេម៉ាយ/ ពោះម៉ាយ ) = 3<br>□ នៅបែកគ្នា =4 |

| | | |
|---|---|---|
| 4 | តើអ្នករស់នៅក្នុងភូមិនេះយូរប៉ុណ្ណាហើយ? | ចំនួន________ ឆ្នាំ |
| 5 | តើមាននុស្សប៉ុន្មាននាក់ស្នាក់នៅក្នុងផ្ទះនេះ? | ចំនួន ________ |
| 6 | តើអ្នកត្រូវជាអ្វីជាមួយមេគ្រួសារ ? | □ មេគ្រួសារ = 01<br>□ ប្ដី ឬ ប្រពន្ធ = 02<br>□ កូនប្រុស= 03<br>□ កូនស្រី= 04<br>□ ម្ដាយ ឬ ឪពុក=05<br>□ ជីដូន ឬ ជីតា 06<br>□ ពូ ឬ មីង ឬ អ៊ំ=07<br>□ ក្មួយប្រុស= 08<br>□ ក្មួយស្រី= 09<br>□ ផ្សេងៗ = 10 |
| 7 | តើអ្វីជាមុខរបរចំបងរបស់អ្នក? | □ អត់ការងារធ្វើ =01<br>□ កសិករ (មានដី)=02<br>□ កសិករប្រវ៉ាស់ (អត់ដី)=03<br>□ កសិករដែលប្រើដីខ្លួនឯងផង និងប្រវ៉ាស់គេផង =04<br>□ មេផ្ទះ=05<br>□ ចិញ្ចឹមសត្វ=06<br>□ លក់កម្លាំងពលកម្មក្នុងវិស័យកសិកម្ម =07<br>□ លក់កម្លាំងពលកម្មក្នុងវិស័យដទៃទៀត=08<br>□ អ្នកនេសាទ=09<br>□ អ្នកធ្វើការតាមផ្ទះ=10<br>□ ជាងដែលមានជំនាញ (ជាងដែក ជាងដេរស្បែកជើង អ្នកតម្បាញ ជាងឈើ) =11<br>□ អ្នកជំនួញខ្នាតតូច=12<br>□ អ្នកជំនួញខ្នាតធំឬមធ្យម=13<br>□ ជាងកាត់ដេរ=14<br>□ អ្នករត់ម៉ូតូឌុប កង់បី និងរត់ទូកជួល=15<br>□ អ្នកបើកឡាន/ព្រូឡាន=16<br>□ គ្រូបង្រៀន=17<br>□ សិស្ស=18<br>□ ចាស់ជរា (អាយុ៦៥ឆ្នាំឡើង)=19<br>□ អ្នកសុំទាន=20<br>□ អ្នកអាស្រ័យអនុផលព្រៃឈើ=21<br>□ ផ្នែកបំរើសេវាកម្ម=22 |

| | | |
|---|---|---|
| | | □ ផ្សេងទៀត បញ្ជាក់=x |
| 8 | តើអ្វីជាប្រភពចំណូលចំបងរបស់គ្រួសារអ្នក? | □ កសិករ (មានដី)=01<br>□ កសិករប្រវ៉ាស់ (អត់ដី)=02<br>□ កសិករដែលប្រើដីខ្លួនឯងផង និងប្រវ៉ាស់គេផង =03<br>□ លក់កម្លាំងពលកម្មក្នុងវិស័យកសិកម្ម =04<br>□ ការងារកម្លាំងពលកម្មក្នុងវិស័យដទៃទៀតក្រៅពីកសិកម្ម=05<br>□ ចិញ្ចឹមសត្វ =06<br>□ អ្នកនេសាទ=07<br>□ អ្នកជំនួញខ្នាតតូច=8<br>□ អ្នកជំនួញខ្នាតធំនិងមធ្យម=9<br>□ ផ្នែកបំរើសេវាកម្ម =10<br>□ ជាងដែលមានជំនាញ (ជាងដែក ជាងដេរស្បែកជើង អ្នកតម្បាញ ជាងឈើ) =11<br>□ អ្នកធ្វើការតាមផ្ទះ =12<br>□ ជាងកាត់ដេរ=13<br>□ អ្នករត់ម៉ូតូឌុប កង់បី និងរត់ទូកដួល=14<br>□ អ្នកបើកឡាន/ព្រូឡាន=15<br>□ គ្រូបង្រៀន=16<br>□ អ្នកសុំទាន=17<br>□ អ្នកអាស្រ័យអនុផលព្រៃឈើ = 18<br>□ ប្រាក់ផ្ញើរពីកន្លែងដទៃ=19<br>□ ផ្សេងទៀត បញ្ជាក់=x |
| 9 | តើផ្ទះអ្នកធ្វើអំពីអ្វី? | □ ស៊ីម៉ង់=1,<br>□ ស៊ីម៉ង់លាយជាមួយធាតុផ្សេង=2,<br>□ សង្កសី=3<br>□ ខ្ទម=4<br>□ ឈើ=5 |

| | សូចនាករ | និយមន័យ | សំណួរ | ពិន្ទុ |
|---|---|---|---|---|
| ផ្នែកសេដ្ឋកិច្ច | | | | |
| 1 | **ចំណូលក្នុងមួយថ្ងៃ** | ជាចំនួនប្រាក់ដែលបុគ្គលម្នាក់រកបានជាមធ្យមប្រចាំថ្ងៃ(ដូចជាការលក់ដូរ, លក់បន្លែ, ទឹកដោះគោ, | 10.តើអ្នកមានរកប្រាក់ចំណូលប្រចាំថ្ងៃដែរឬទេ? | បាទ/ចាស = 1 (គិតតែអ្នកដែលមានចំណូលប្រចាំថ្ងៃតែប៉ុណ្ណោះ) |

| | | | | |
|---|---|---|---|---|
| | | ផលិតផលធ្វើដោយដៃ, ការងារលក់កម្លាំងបានប្រាក់ប្រចាំថ្ងៃ) | | ទេ = 0 |
| | | | 11. គិតជាមធ្យម តើអ្នករកចំណូលបានប៉ុន្មានក្នុង១ថ្ងៃ? | តិចជា ១.៩០ ដុល្លា = 0<br>ចន្លោះ ១.៩០ ដល់ ៤.២ ដុល្លា = 1<br>ច្រើនជាង ៤.២ ដុល្លា = 2 |
| | | | 12. គិតជាមធ្យម តើគ្រួសារអ្នករកប្រាក់ចំណូលបានប៉ុន្មានក្នុង១ខែ? | តិចជា ២២០  ដុល្លា = 0<br>ចន្លោះ ២២០ ដល់ ៤៨៧ ដុល្លា = 1<br>ច្រើនជាង ៤៨៧ ដុល្លា = 2<br>មិនដឹង = 99 (មុនហ្នឹងជ្រើសរើសកូដ មិនដឹង, សូមសួរបញ្ជាក់ពីប្រាក់ចំណូលមធ្យមរបស់គ្រួសារអ្នកតបយ៉ាងហោចណាស់ 3 លើក និងបង្ហាញចម្លើយកូដ (0-3)អោយអ្នកតបជ្រើសរើសជាមុនសិន) |
| | | | 13. តើគ្រួសារអ្នកអាចសន្សំលុយបានខ្លះទេក្នុង១ខែ? | បាទ/ចាស រៀងរាល់ខែ = 2<br>ម្តងម្កាល = 1<br>មិនដែល = 0<br>មិនដឹង (មុនហ្នឹងជ្រើសរើសកូដ មិនដឹង, សូមសួរបញ្ជាក់អ្នកតប យ៉ាងហោចណាស់ 3 លើកជាមុនសិន) |
| 3 | **ការទទួលបានប្រភពចំណូលដែលមានស្ថេរភាព និងសុវត្ថិភាពរបស់អ្នកតបសម្ភាសន៍** | ដើម្បីពិនិត្យមើលស្ថេរភាព និងជម្រើសជីវភាពផ្សេងៗ | 14. តើគ្រួសារអ្នកមានប្រភពប្រាក់ចំណូលប៉ុន្មានប្រភពដែរ? | រាប់ប្រភេទការងារមិនមែនរាប់ចំនួនអ្នកធ្វើការទេ |
| | | | 15. តើប្រាក់ចំណូលរបស់អ្នករកបានទៀងទាត់ពេញ១ឆ្នាំទេ? | បាទ/ចាស = 2<br>ចំណូលថេរយ៉ាងហោចណាស់ ៦ខែ = 1 |

| | | | | |
|---|---|---|---|---|
| | | | | ទេ, មិនថេរ / មិនថេរច្រើនជាង ៦ខែ = 0 |
| 4 | **លទ្ធភាពកម្ចីផ្លូវការ និងក្រៅផ្លូវការ** | លទ្ធភាពកម្ចី: សិទ្ធិ និងសមត្ថភាពក្នុងការប្រើប្រាស់ប្រាស់កម្ចី/ឥណទាន | 16. តើអ្នកយល់ថាអ្នកអាចខ្ចីប្រាក់គេបាន នៅពេលអ្នកត្រូវការ? | បាន = 1<br><br>អត់បាន = 0 |
| | | | 17. ប្រសិនបើអ្នកបានខ្ចីហើយ តើអ្នកយកលុយនោះមកពីប្រភពណា?ប្រសិនអ្នកមិនទាន់បានខ្ចីតើអ្នកគិតថាអាចរកខ្ចីបានពីប្រភពណា នៅពេលអ្នកត្រូវការ?<br><br>[ក្នុងករណីដែលអ្នកតបអាចខ្ចីបានច្រើនប្រភព សួរគាត់បញ្ជាក់ថា តើប្រភពណាដែលគាត់មានសុវត្ថិភាព និងងាយខ្ចីជាងគេ] | មិនត្រូវស្ថានភាព=0<br><br>ស្ថាប័នឯកជនឬបុគ្គលដែលមានការប្រាក់ខ្ពស់ (ចងការគេ) =0<br><br>អាចខ្ចីបានច្រើនកន្លែង (អាចខ្ចីបានទាំងប្រភពដែលមានការប្រាក់ខ្ពស់ផង ទាបផង)=1<br><br>ធនាគារ ឬមីក្រូហ្វាយណាន់ =2<br><br>ក្រុមជួយខ្លួនឯង មិត្តភក្តិ អ្នកជិតខាង =3<br><br>ឥឡូវនេះ យ៉ាងណាក៏ខ្ញុំមិនខ្ចីគេដែរ = 4 |
| | | | 18.តើអ្នកអាចសងលុយទៅគេវិញទៅតាមពេលកំណត់ទេ? | ទេ = 0<br><br>មិនត្រូវស្ថានភាព =1 |
| | | | 19. តើអ្នកអាចខ្ចីប្រាក់ពីរដ្ឋាភិបាលបានទេ នៅពេលដែលអ្នកត្រូវការ? | បាទ/ចាស =1<br><br>ទេ /មិនដឹង = 0 |
| 5 | **ការគ្រប់គ្រងលើការចំណាយ** | ដើម្បីវាស់វែងពីកម្រិតនៃចាត់ចែងការចំណាយរបស់អ្នកតបដែលបានមកពីចំណូលរបស់គាត់ និងគ្រួសារគាត់ | 20. តើអ្នកជាអ្នកចាត់ចែងលុយដែលអ្នករកដោយខ្លួនឯងដែរឬទេ? | បាទ/ចាស, ខ្ញុំជាអ្នក ចាត់ចែងច្រើនជាងគេ ឬស្មើគេ= ២<br><br>បាទ/ចាស, ខ្ញុំអាចចាត់ចែងបានតាមតែផ្នែកទេ = 1<br><br>ទេ = 0 |

| | | | | |
|---|---|---|---|---|
| | | | 21. តើអ្នកជាអ្នកចាត់ចែងប្រាក់ចំណូលដែលក្រុមគ្រួសារទាំងមូលរកបាន ដែរឬទេ? | បាទ/ចាស, ខ្ញុំជាអ្នកចាត់ចែងច្រើនជាងគេ ឬស្មើរគេ= 2<br>បាទ/ចាស, ខ្ញុំចាត់ចែងបានតែតាមផ្នែកទេ = 1<br>ទេ = 0 |
| 6 | **កម្មសិទ្ធិដីធ្លី** | ដើម្បីវាស់វែងពីការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី | 22.តើអ្នកជាម្ចាស់កម្មសិទ្ធិលើដីលំនៅដ្ឋាន/ផ្ទះដែលអ្នកកំពុងរស់នៅដែលឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 23.តើអ្នកត្រូវចំណាយលុយជួលដីដែលអ្នកកំពុងប្រើប្រាស់ដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| 7 | **ការរកបាន និងប្រើប្រាស់ធនធានធម្មជាតិ និងសត្វចិញ្ចឹមដើម្បីទ្រទ្រង់ជីវភាព** | ដើម្បីវាស់វែងពីការរកបាន និងប្រើប្រាស់ធនធានធម្មជាតិដែលពួកគាត់ត្រូវការ(ដូចជាដី,សត្វចិញ្ចឹម,ទឹក,ព្រៃ,ជលផលនិងជីវចម្រុះ) ក្នុងការទ្រទ្រង់ជីវភាពរបស់ពួកគាត់ | 24. តើអ្នកជួបការលំបាកក្នុងការទាញផល/ប្រើជានជានធម្មជាតិ (ដូចជាដី,សត្វចិញ្ចឹម,ទឹក,ព្រៃ,ជលផលនិងជីវចម្រុះ) ដែលអ្នកត្រូវការសម្រាប់ជីវភាពរបស់អ្នកដែរឬទេ ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 25. តើអ្នកត្រូវបង់ប្រាក់ ដើម្បីប្រើដី, ទឹក ឬទាញអនុផលព្រៃឈើ ដែលអ្នកត្រូវការប្រើសម្រាប់ទ្រទ្រង់ជីវភាពដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 26. តើអ្នកមានចិញ្ចឹមសត្វសម្រាប់បរិភោគ ឬលក់ដែររឺទេ? | បាទ/ចាស =1<br>ទេ = 0 |
| 8 | **និរន្តភាព និងធនធានធម្មជាតិ និងប្រភពគាំទ្រជីវភាពនានា** | ដើម្បីវាស់វែងពីនិរន្តភាព/ភាពយូរអង្វែង បរិមាណ និងគុណភាពនៃធនធានធម្មជាតិ ដូចជាដី, ព្រៃ, ទឹក, សត្វចិញ្ចឹម និងជីវចម្រុះ) ដែលពួកគាត់ប្រើប្រាស់សម្រាប់ទ្រទ្រង់ជីវភាព។ | 27. តើគុណភាពនៃធនធានធម្មជាតិ (ដី, ទឹក, ជលផល, ព្រៃ, សត្វចិញ្ចឹម និងជីវៈចម្រុះ) ដែលអ្នកត្រូវការសម្រាប់ជីវភាពមានការប្រែប្រួលបរិមាណយ៉ាងដូចម្តេច? ឧទាហរណ៍. ទឹកបំពុលជាងមុនឬល្អជាងមុន ឬ | ប្រសើរជាងពីមុន = 2<br>ដូចតែមុន = 1<br>អាក្រក់ជាងមុន = 0 |

| | | | | |
|---|---|---|---|---|
| | | ពាក្យថាការប្រកួតប្រជែងលើធនធានធម្មជាតិនៅទីនេះ សំដៅដល់ការដណ្តើមជាមួយសមាជិកក្នុងសហគមន៍ ឬអ្នកខាងក្រៅដើម្បីទាញយកផលពីធនធានធម្មជាតិ (ឧទាហរណ៍. មានតម្រូវការច្រើនលើសពីធនធានធម្មជាតិដែលមាន)។ ចំណែកពាក្យថា ជីវភាព សំដៅដល់ការធ្វើអោយរស់រានមានជីវិត មិនមែនសំដៅតែលើការរកប្រាក់ចំណូលមួយមុខទេ | ដីខ្សោះជីជាតិ/ឬមានជីជាតិជាងមុន? | |
| | | | 28. តើបរិមាណនៃធនធានធម្មជាតិ (ដី, ទឹក, ដលផល, ព្រៃ, សត្វចិញ្ចឹម និងជីវៈចម្រុះ) ដែលអ្នកត្រូវការសម្រាប់ជីវភាពមានការប្រែប្រួលបរិមាណយ៉ាងដូចម្តេច? ទឹកតិចឬច្រើនជាងមុន/សត្វចញ្ចឹមមានច្រើនឬតិចជាងមុន? | ច្រើនជាងមុន = 2<br>ដូចតែមុន = 1<br>តិចជាងមុន = 0 |
| | | | 29. ក្នុងការទាញផលពីធនធានធម្មជាតិ (ដី, ទឹក, ដលផល, ព្រៃ, សត្វចិញ្ចឹម និងជីវៈចម្រុះ) តើមានការប្រកួតប្រជែងឬដណ្តើមគ្នាជាមួយអ្នកក្នុងសហគមន៍/ភូមិឃុំ ឬអ្នកខាងក្រៅដែលធ្វើអោយប៉ះពាល់ដល់ជីវភាពរបស់អ្នកដែរឬទេ? ឧទាហរណ៍ដោយសារមានអ្នកនេសាទច្រើនធ្វើអោយអ្នកពិបាករកដលផល, អនុផលព្រៃឈើថយចុះដោយសារតម្រូវការច្រើន និងមានអ្នករកច្រើន, ការរំលោភបំពានដីធ្លីដែលធ្វើអោយអ្នកពិបាកធ្វើកសិកម្ម ជាដើម? | បាទ/ចាស = 0<br>ទេ =1 |
| | | | 30. តើគម្រោងអភិវឌ្ឍកន្លងមកបានធ្វើឱ្យអ្នកកាន់តែងាយរងផលប៉ះពាល់ពីគ្រោះមហន្តរាយដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| 9 | **លទ្ធភាពទៅទីផ្សារ** | សិទ្ធិ និងលទ្ធភាពទៅផ្សារដើម្បីលក់ដូរផលិតផល ឬសេវាកម្ម | 31. តើអ្នកអាចទៅផ្សារមួយ ឬលើសពីហ្នឹងដែរឬទេ? | បាទ/ចាស, អាចទៅបានពីរបី = 2 |

| | | | | |
|---|---|---|---|---|
| | | | | បាទ/ចាស, ទៅបានតែមួយ = 1<br><br>ទេ = 0 |
| | | | 32. ប្រសិនបើអ្នកមានផលិតផលចង់លក់ដូរ តើអ្នកអាចសម្រេចចិត្តបានទេថាត្រូវយករបស់ទៅលក់នៅកន្លែងណាបានដែរឬទេ ? | បាទ/ចាស =1<br><br>ទេ = 0 |
| | | | 33. ប្រសិនបើអ្នកចង់ទិញផលិតផលណាមួយ តើអ្នកអាចសម្រេចចិត្តបានទេថាត្រូវទិញរបស់នៅកន្លែងណាបានដែរឬទេ ? | បាទ/ចាស =1<br><br>ទេ = 0 |
| | | | 34. នៅពេលមានគ្រោះមហន្តរាយកើតឡើង តើអ្នកមិនអាចទៅផ្សារបានទេមែនទេ ? | បាទ/ចាស = 0 ( បាទ/ចាស នៅទីនេះមានន័យថា គាត់មិនអាចទៅផ្សារបានទេ ដោយសារមានគ្រោះមហន្តរាយ )<br><br>ទេ =1 ( ទេ នៅទីនេះ មានន័យថា គាត់អាចទៅផ្សារបាន បើទោះបីមានគ្រោះមហន្តរាយ ) |
| **ផ្នែកហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| 10 | **ភាពរឹងមាំ/ធន់នៃផ្ទះ** | ដើម្បីវាស់វែងថា តើអ្នកឆ្លើយសំណួរគិតយ៉ាងដូចម្តេចពីសំណង់ផ្ទះរបស់ពួកគាត់ ថាតើវាអាចទប់ទល់/ធន់ និងស្រាកស្រាន្តវិញលឿនកម្រិតណា ប្រសិនបើមានគ្រោះធម្មជាតិកើតឡើង។<br><br>ពាក្យថាគ្រោះធម្មជាតិនេះ គឺសំដៅដល់ទាំងព្រឹត្តិការណ៍គ្រោះធម្មជាតិរយៈពេលវែង( ឧ.រាំងស្ងួត ) និងរយៈពេលខ្លី ( ឧ.ខ្យល់ព្យុះ ឬទឹកជំនន់។ ក្នុងហ្នឹងផងដែរសូចនាករនេះគឺវាស់ស្ទង់ថាតើអ្នកគបយល់ថាផ្ទះ | 35.តើអ្នកមានអារម្មណ៍ថាផ្ទះរបស់អ្នកមានសុវត្ថិភាពដែរឬទេ ? | បាទ/ចាស =1<br><br>ទេ = 0 |
| | | | 36. តើអ្នកដឹងដែរឬទេថាមានច្បាប់ស្តីពីការសាងសង់ ហើយបើមាន តើមានការអនុវត្តដែរឬទេ ? | បាទ/ចាស មានច្បាប់ហើយត្រូវបានអនុវត្ត = 3<br><br>បាទ/ចាស មានតែមិនត្រូវបានអនុវត្ត= 2<br><br>ទេ = 1<br><br>មិនដឹង = 0 |

| | | | | |
|---|---|---|---|---|
| | | របស់គាត់ស្ថិតនៅទីតាំងដែលមាន ឬមិនមានគ្រោះថ្នាក់ហានិភ័យផ្សេងៗ | | |
| 11 | **ការរស់នៅក្នុងទីតាំងមានសុវត្ថិភាព** | ដើម្បីវាស់ស្ទង់អ្នកតបសម្ភាសន៍ថាតើ ពួកគាត់គិតថាផ្ទះរបស់ពួកគាត់ស្ថិតនៅក្នុងតំបន់ដែលមិនមានហានិភ័យនៃគ្រោះថ្នាក់ | 37. តើអ្នកមានអារម្មណ៍ថាផ្ទះរបស់អ្នកស្ថិតនៅក្នុងតំបន់ដែលមានសុវត្ថិភាពដែរឬទេ? | បាទ/ចាស =1<br><br>ទេ = 0 |
| | | | 38.តើផ្ទះរបស់អ្នកងាយនឹងរងគ្រោះដោយសារគ្រោះមហន្តរាយដែរឬទេ? | បាទ/ចាស = 0<br><br>ទេ =1 |
| | | | 39.តើផ្ទះអ្នកសង់នៅកន្លែងមិនស្របច្បាប់ដែរឬទេ? | បាទ/ចាស = 0 (បាទ/ចាស នៅទីនេះមានន័យថា ផ្ទះរបស់គាត់សង់នៅកន្លែងមិនស្របច្បាប់)<br><br>ទេ =1 (ទេ នៅទីនេះ មានន័យថា ផ្ទះរបស់គាត់សង់នៅកន្លែងស្របច្បាប់) |
| | | | 40. តើមានច្បាប់ (ច្បាប់/អនុក្រិត/ប្រកាស/សេចក្តីជូនដំណឹង/សេចក្តីណែនាំ ឬផែនការដែលចេញដោយសភា, រដ្ឋាភិបាល/អាជ្ញាធរ ) ពីការប្រើប្រាស់ដីដែរឬទេ, ហើយបើមានវាត្រូវបានគេអនុវត្តដែរឬទេ? | បាទ/ចាស មានច្បាប់ហើយត្រូវបានអនុវត្ត = 3<br><br>បាទ/ចាស មានតែមិនត្រូវបានអនុវត្ត= 2<br><br>ទេ = 1<br><br>មិនដឹង = 0 |
| 12 | **ការពឹងផ្អែកទៅលើការប្រើប្រាស់មធ្យោបាយធ្វើដំណើរ** | ដើម្បីវាស់ស្ទង់ពីសមត្ថភាពរបស់អ្នកតបសម្ភាសន៍ ក្នុងការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត នៅតាមផ្លូវ ដែលអាចទុកចិត្តបាន និងបានថែទាំទៅតាមស្តង់ដាល្អ | 41.ប្រសិនបើអ្នកត្រូវធ្វើដំណើរចេញពីភូមិ តាមផ្លូវគោក ឬផ្លូវទឹក តើអ្នកអាចធ្វើដំណើរបានពេញ១ឆ្នាំដែរឬទេ? | បាទ/ចាស =1<br><br>ទេ = 0 |
| | | | 42. តើអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពដែរឬទេ នៅពេលប្រើប្រាស់ផ្លូវទាំងអស់នោះ? | បាទ/ចាស =1<br><br>ទេ = 0 |

| | | | | |
|---|---|---|---|---|
| | | | 43.តើផ្លូវទាំងអស់នោះមានស្ថានភាពយ៉ាងដូចម្តេច? | ល្អ = 2<br>អាស្រ័យលើធាតុអាកាស = 1<br>មិនល្អទេ= 0 |
| 13 | **លទ្ធភាពនៃការប្រើប្រាស់ថាមពលដែលមានតម្លៃសមរម្យ** | ដើម្បីវាស់វែងពីការប្រើប្រាស់ថាមពលពីប្រភពផ្សេងៗរបស់អ្នកតបសម្ភាសន៍ និងសមត្ថភាពរបស់ពួកគាត់ដើម្បីរកបានថាមពលទាំងនោះប្រកបដោយសុវត្ថិភាព ក្នុង១ឆ្នាំៗ *?* | 44. តើអ្នកប្រើថាមពលអគ្គីសនីបានទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 45. តើប្រភពថាមពលអ្វីខ្លះដែលអ្នកប្រើជាប្រចាំ (ឧ. អគ្គីសនី សូឡា អុស លាមកគោក ឥន្ធនៈ ហ្គាស)? | សរសេរចំនួននៃប្រភពថាមពល |
| | | | 46. តើអ្នកមានលទ្ធភាពចំណាយលើថាមពលទាំងនោះ (ប្រភពថាមពលនៅសំណួរ 45) ពេញ១ឆ្នាំដែរទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 47. តើប្រភពថាមពលដែលអ្នកប្រើប្រាស់ បង្កហានិភ័យដល់សុខភាព/បញ្ហាផ្សេងៗ (បញ្ហាផ្លូវដង្ហើម ឆេះរាងកាយ ឆ្លងភ្លើង) ដែរឬទេ? | បាទ/ចាស = 0<br>ម្តងម្កាល = 1<br>ទេ = 2 |
| | | | 48. ជាទូទៅ តើអ្នកអាចប្រើថាមពល (ដែលចាំបាច់សម្រាប់តម្រូវការរបស់អ្នក) ពេញ១ឆ្នាំដែរទេ? | បាទ/ចាស =1<br>ទេ = 0 |
| 14 | **ការប្រើបច្ចេកវិទ្យាទំនាក់ទំនង** | លទ្ធភាពនៃការប្រើអ៊ីនធើណិតប្រព័ន្ធអត់ខ្សែ(វ៉ាយហ្វាយ) ទូរសព្ទដៃ និងប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗទៀត | 49. តើអ្នក ប្រើទូរសព្ទដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 50. តើអ្នក ប្រើអ៊ីនធើណិតដែរទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 51. តើអ្នក ប្រើវិទ្យុដែរទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 52. តើអ្នក ប្រើទូរទស្សន៍ដែរទេ? | បាទ/ចាស =1 |

| | | | | |
|---|---|---|---|---|
| | | | | ទេ = 0 |
| 15 | **ការទទួលយកបាន និងប្រសិទ្ធភាពនៃប្រព័ន្ធប្រកាសឲ្យដឹងមុន** | ដើម្បីវាស់វែងអ្នកតបសម្ភាសន៍ថាតើ គាត់មានទទួលបានប្រព័ន្ធប្រកាសអោយដឹងមុនទាន់ពេល, យល់ឬអត់ ហើយទុកចិត្តឬអត់ | 53. សូមគិតពីព្រឹត្តិការណ៍ធាតុអាកាស/គ្រោះថ្នាក់ដែលបានកើតឡើងចុងក្រោយនេះ, តើអ្នកបានដឹងទុកជាមុនដែរទេ? | បាទ/ចាស, ខ្ញុំបានទទួលដំណឹងមុន ហើយខ្ញុំយល់ពីដំណឹងនោះ = 2<br>បាទ/ចាស ខ្ញុំបានទទួលដំណឹងនោះដែរ តែខ្ញុំមិនយល់ទេ = 1<br>ទេ, ខ្ញុំមិនបានទទួលដំណឹងមុនទេ = 0 |
| | | | 54. តើអ្នកជឿលើការជូនដំណឹងជាមុននោះ និងអនុវត្តសកម្មភាពអ្វីដែរឬទេ នៅពេលនោះ? | បាទ/ចាស =1<br>ទេ = 0 |
| 16 | **ការប្រើធាតុចូលកសិកម្ម និងឧបករណ៍នានាសម្រាប់ជីវភាពរស់នៅ** | ដើម្បីប៉ាន់ប្រម៉ាណពីធាតុចូលផ្សេងៗ (ដូចជាជី ថ្នាំសម្លាប់សត្វល្អិត និងពូជ) និងឧបករណ៍(សម្រាប់គ្រឿងម៉ាស៊ីន ដូចជាត្រាក់ទ័រ) សម្រាប់ជួយគាំទ្រដល់ជីវភាពរបស់អ្នកឆ្លើយតប | 55. សម្រាប់ការទ្រទ្រង់ជីវភាពរបស់អ្នក តើអ្នកប្រើធាតុចូលកសិកម្ម(ជី ថ្នាំសម្លាប់សត្វល្អិត និងពូជ) ឬ ឧបករណ៍គ្រឿងម៉ាស៊ីន ដូចជាត្រាក់ទ័រ ឬគោយន្ត ដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 56. តើធាតុចូល និងបច្ចេកវិទ្យា (ជី ថ្នាំសម្លាប់សត្វល្អិត និងពូជ និងឧបករណ៍គ្រឿងម៉ាស៊ីន ដូចជាត្រាក់ទ័រ ឬគោយន្ត) ទាំងអស់នោះគិតគូរពីបរិស្ថាន ឬ ល្អសម្រាប់បរិស្ថានដែរទេ? | បាទ/ចាស =1<br>ទេ = 0 |
| 17 | **ការប្រើប្រាស់ទឹកផឹក និងសម្រាប់ការងារផ្ទះ** | ដើម្បីវាយតម្លៃពីការរក និងប្រើប្រាស់ទឹកសម្រាប់ផឹក បោកសំអាត និងការងារផ្ទះ។<br>ទឹកស្អាតគឺជាទឹកដាំពុះ ទឹកចម្រោះ ទឹករដ្ឋ (ភ្នំពេញ) ទឹកបរិសុទ្ធ និងទឹកអណ្ដូងស្នប់ | 57. តើអ្នកមានទឹកដែលមានសុវត្ថិភាពសម្រាប់ផឹកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 58. តើអ្នកមានទឹកដែលមានសុវត្ថិភាពនោះ ពេញ១ឆ្នាំដែរទេ? | បាទ/ចាស =1<br>ទេ = 0 |

| | | | | |
|---|---|---|---|---|
| | | | 59. តើអ្នកមានទឹកស្អាតសម្រាប់ចំអិនអាហារ និងការងារផ្ទះដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 60. តើអ្នកត្រូវដើរច្រើនជាង ៥០០ម៉ែត្រ ដើម្បីបានទឹកប្រើប្រាស់ដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 61. តើអ្នកមានទៅយក (ដង, រែក, យួរ, ដឹក...) ទឹកមកទុកប្រើប្រាស់ក្នុងគ្រួសារអ្នកដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| 18 | **ការមានអនាម័យសមរម្យ និងសុវត្ថិភាព** | ដើម្បីវាស់វែងពីលទ្ធភាពរបស់មនុស្សម្នាក់ក្នុងការប្រើប្រាស់អនាម័យ (បង្គន់)ជាមួយនឹងការពេញចិត្តលើ គុណភាព និងសុវត្ថិភាព នឹងការដែលទៅដល់បានងាយស្រួល | 62. តើផ្ទះអ្នកមានបង្គន់អនាម័យទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 63. តើអ្នកមានអារម្មណ៍ថាសុវត្ថិភាពពេលប្រើប្រាស់បង្គន់ហ្នឹងដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 64. តើអ្នកបន្ទោរបង់នៅខាងក្រៅទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 65. តើមានប្រព័ន្ធគ្រប់គ្រងកាកសំណល់ (លូបង្ហូរទឹកស្អុយ) នៅក្នុងភូមិនេះដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| 19 | **ការការពារបែបរូបវន្តពីគ្រោះធម្មជាតិ** | ដើម្បីវាស់ស្ទង់ពីការបន្សាំបែបរូបវន្តដែលមានដូចជា( ដូចជា ទំនប់ការពារទឹក របាំងការពារទឹកជំនន់, អាងស្តុកទឹកសម្រាប់ការពារគ្រោះរាំងស្ងួត, ប្រព័ន្ធលូរំដោះទឹក ជាដើម ដែលមានសម្រាប់កាពាររមនុស្សពីគ្រោះមហន្តរាយធម្មជាតិ និងក៏ដូចជាវាស់វែងពីស្ថានភាពរបស់វា | 66. ក្នុងការការពារអ្នកពីគ្រោះធម្មជាតិ តើមានវិធានការបែបរូបវន្ត (ដូចជា ទំនប់ការពារទឹក របាំងការពារទឹកជំនន់, អាងស្តុកទឹកសម្រាប់ការពារគ្រោះរាំងស្ងួត, ប្រព័ន្ធលូរំដោះទឹក ជាដើម) ដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 67. តើមានវិធានការបែបរូបវន្ត (ដូចជា ទំនប់ការពារទឹក របាំងការពារទឹកជំនន់, អាងស្តុកទឹកសម្រាប់ការពារគ្រោះរាំងស្ងួត, | បាទ/ចាស =1<br>ទេ = 0 |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធលូរំដោះទឹក ជាដើម) មានគុណភាពល្អដែរឬទេ? | |
| | | | 68. តើអ្នកគិតថារបស់ទាំងនោះគ្រប់គ្រាន់ឬនៅ? | បាទ/ចាស =1<br>ទេ = 0 |
| 20 | **ជម្រក/កន្លែងសុវត្ថិភាព** | ដើម្បីវាស់ស្ទង់ចំណេះដឹងពីសុវត្ថិភាពរបស់អ្នកតបសម្ភាសន៍ទាំងមុនពេល កំឡុងពេល និងក្រោយពេលមានគ្រោះអាសន្ន ទាក់ទងនឹងការដែលអាចទៅបាន និងមានសុវត្ថិភាពជាដើម | 69. តើអ្នកដឹងថា មានជម្រកឬទីសុវត្ថិភាព សម្រាប់ភាសខ្លួននៅមុនពេល កំឡុងពេល និងក្រោយពេលមានអាសន្នដែរឬទេ?<br>[ប្រសិនបើQ69=0, Q70 & Q71 ត្រូវតែ=0 ដែរ] | បាទ/ចាស =1<br>ទេ = 0<br>មិនដឹង= 0 |
| | | | 70. តើជម្រក/កន្លែងសុវត្ថិភាពអាចទៅបានដែរឬទេ?<br>(ចំងាយ ពិការភាព ការគិតគូរពីស្ត្រី កុមារនិងមនុស្សចាស់) | បាទ/ចាស =1<br>ទេ = 0<br>មិនដឹង= 0 |
| | | | 71. តើអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពដែរឬទេនៅទីសុវត្ថិភាពនោះ? | បាទ/ចាស =1<br>ទេ = 0<br>មិនដឹង= 0 |
| | | | 72. ប្រសិនបើអ្នកបានដឹងដំណឹងមុនពីអាសន្ន តើអ្នកនឹងទៅទីសុវត្ថិភាពនោះដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| **ផ្នែកសង្គម** | | | | |
| 21 | **ការទទួលបានការអប់រំក្នុងប្រព័ន្ធ** | ដើម្បីវាស់វែងពីកម្រិតអប់រំភាគច្រើនក្នុងប្រព័ន្ធរបស់ប្រជាពលរដ្ឋ និងភាពស្មើគ្នានៃរវាងក្មេងប្រុស និងក្មេងស្រី | 73. តើអ្នកបានទៅរៀនដល់ថ្នាក់ណា? | មិនបានទៅរៀន =0<br>ថ្នាក់មតេយ្យសិក្សា =1<br>ថ្នាក់បឋមសិក្សា (ថ្នាក់ទី1-6) =2<br>ថ្នាក់អនុវិទ្យាល័យ (7-9) =3<br>ថ្នាក់វិទ្យាល័យ (10-12) =4<br>ថ្នាក់បរិញ្ញាប័ត្រ = 5 |

| | | | | |
|---|---|---|---|---|
| | | | | ថ្នាក់ក្រោយបិរញ្ញាប័ត្រ - អនុបណ្ឌិត/បណ្ឌិត = 6 |
| | | | 74.តើអ្នកបានរៀនអក្សរតាមកម្មវិធីផ្សេងទេ? (ឧទាហរណ៍ ថ្នាក់អក្ខរកម្ម រៀននៅវត្ត ជាដើម) | បាទ/ចាស =1<br>ទេ = 0 |
| | | | 75. តើមានសាលាបឋមសិក្សានៅក្នុងតំបន់របស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 76. តើមានសាលាអនុវិទ្យាល័យនៅក្នុងតំបន់របស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 77. តើអ្នកដឹងថា កុមារៗបានរៀនអំពីគ្រោះមហន្តរាយទេនៅសាលារបស់ពួកគេដែរឬទេ? | បាទ/ចាស, ពួកគេរៀន =1<br>ទេ/ខ្ញុំមិនដឹងដែរ =0 |
| 22 | **ការទទួលបានព័ត៌មាន និងការប្រើប្រាស់ចំណេះដឹងក្នុងស្រុក** | ដើម្បីប៉ាន់ប្រមាណពីប្រភេទព័ត៌មានដែលប្រជាជនក្នុងទទួលបាន, របៀបក្នុងការប្រើប្រាស់ និងការប្រើប្រាស់ចំណេះដឹងបានពីមូលដ្ឋាន ឬ ប្រពៃណី (ចំណេះដឹងដែលបានអភិវឌ្ឍន៍ និងបន្តអភិវឌ្ឍន៍ជាបន្តបន្ទាប់ ដោយផ្អែកលើបទពិសោធន៍, វប្បធម៌តាមមូលដ្ឋាន, បរិបទ និងបរិស្ថាន។ | 78. តើអ្នកអាចអាននិងសរសេរបានទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 79. តើអ្នក មើល ស្តាប់ ឬអានព័ត៌មានក្នុងស្រុករបស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 80. តើអ្នកទទួលបានពត៌មានទូទៅពីប្រភពពត៌មានផ្លូវការ (ពីរដ្ឋាភិបាល) ឬទេ? (ឧទាហរណ៍ ព្យាករណ៍អាកាសធាតុ, តម្លៃដំណាំកសិកម្ម គម្រោងគាំទ្ររបស់រដ្ឋាភិបាល ឬការប្រកាសផ្សេងៗជាដើម) | បាទ/ចាស =1<br>ទេ = 0 |
| | | | 81. តើអ្នកទទួលបានពត៌មានទូទៅពីប្រភពពត៌មានក្រៅផ្លូវ | បាទ/ចាស =1 |

| | | | | |
|---|---|---|---|---|
| | | | ការដទៃទៀត ឬទេ? (ឧទាហរណ៍ ពីញាតិមិត្ត ឬអ្នកជិតខាង) | ទេ = 0 |
| | | | 82. តើអ្នកពឹងផ្អែកលើចំណេះដឹងបែបបុរាណឬ តាមតំបន់របស់អ្នក សម្រាប់ការរៀបចំដោះស្រាយនិងឆ្លើយតបចំពោះគ្រោះមហន្តរាយដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| 23 | **ការទទួលបានតំលៃសមរម្យនៃសុខាភិបាល** | ដើម្បីប៉ាន់ប្រមាណពីប្រភេទនៃសេវាសុខាភិបាលដែលប្រជាជនអាចរកបាន ហ្នឹងថាតើវាមានតម្លៃសមរម្យឬអត់ (មានន័យថា គាត់អាចបង់ថ្លៃបានដោយប្រើលុយចំណូល/ឬការសន្សំរបស់កាត់) និងតើការថែទាំសុខភាពសមរម្យត្រូវតែម្រូវការ (អាចព្យាបាលអោយជាសះស្បើយ) ពួកគាត់ឬទេ | 83. តើសេវាសុខាភិបាលប្រភេទណាដែលអ្នកមានលទ្ធភាពអាចទៅរកបាន? | ច្រើនកន្លែងទាំងសេវាថែទាំព្យាបាលបែបបូរាណ និងផ្លូវការ=3<br>ពេទ្យរដ្ឋ/អង្គភាពសុខភាពមូលដ្ឋាន=2<br>ពេទ្យឯកជន/បុគ្គលិកពេទ្យ=1<br>ព្យាបាលតាមបែបបុរាណតែមួយគត់=1<br>មិនអាចទៅរកបានសេវាថែទាំសុខភាពអ្វីនោះទេ=0 |
| | | | 84. តើអ្នកពេញចិត្តជាមួយនឹងសេវាដែលផ្តល់ឱ្យនោះដែរឬទេ? [បើសំណួរ 83=0, សូមរើសកូដ 0 នៅក្នុងសំណួរ 84] | បាទ/ចាស =1<br>ទេ = 0 |
| | | | 85. តើអ្នកឬសមាជិកគ្រួសារអ្នកអាចទៅរកធ្មបដែលមានជំនាញត្រឹមត្រូវដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 86. តើអ្នកឬសមាជិកគ្រួសារអ្នកអាចទៅរកសេវាថែទាំពោះមុននិងក្រោយសម្រាលដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 87. នៅពេលត្រូវទៅពេទ្យ តើអ្នកអាចមានមធ្យោបាយ (មានយាន្តជំនិះ ឬមានប្រាក់សម្រាប់ | បាទ/ចាស =1<br>ទេ = 0 |

| | | | | |
|---|---|---|---|---|
| | | | ធ្វើដំណើរ) ទៅដោយខ្លួនឯង ឬអត់? | |
| | | | 88. ដើម្បីអាចទទួលបានសេវាថែទាំសុខភាព, តើអ្នកត្រូវការជួលអ្នកនាំ ឬ ភ្នាក់ងារណាម្នាក់ដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 89. តើអ្នកមានប័ណ្ណធានារ៉ាប់រងសុខភាព, ប័ណ្ណសមធម៌, ប័ណ្ណប.ស.ស ឬ ប័ណ្ណក្រីក្រដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| 24 | **សន្តិសុខស្បៀង /សុវត្ថិភាពអាហារូបត្ថម្ភ** | វាស់វែងពីលទ្ធភាពរបស់អ្នកតបក្នុងការរកបាននូវអាហារគ្រប់គ្រាន់ និងមានអាហារូបត្ថម | 90. តើមានអាហារគ្រប់គ្រាន់សម្រាប់សមាជិកក្នុងផ្ទះញ៉ាំបានគ្រប់គ្នា ហើយគ្រប់គ្រាន់ពេញ១ឆ្នាំដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 91. តើអ្នកគិតថារបបអាហារប្រចាំសប្តាហ៍របស់អ្នកបានគ្រប់ទាំង៣ក្រុម (គ្រាប់ធញ្ញជាតិដូចជាបាយ/ពោតដាដើម បន្លែ/ផ្លែឈើ ត្រី/សាច់ និងស៊ុត ) ដែរឬទេ? | បាទ/ចាស, ខ្ញុំញ៉ាំទាំង3មុខ = 3<br>បាទ/ចាស, ខ្ញុំញ៉ាំ2មុខ<br>ទេ, ខ្ញុំញ៉ាំតែមួយមុខទេ=1 |
| | | | 92. តើរបបអាហារ(ទាំងបីក្រុម)របស់អ្នកមានភាពប្រសើរឡើងឬទេក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ? | បាទ/ចាស ប្រសើរជាងមុន = 2<br>ដូចតែមុន = 1<br>ទេ/មានការថយចុះ = 0 |
| 25 | **របេទសង្គម** | ដើម្បីវាស់ស្ទង់សិទ្ធិសេរីភាពនិងសមត្ថភាពក្នុងការដើរហើរ | 93. តើអ្នកត្រូវសុំការអនុញ្ញាតិពីអ្នកផ្ទះទេពេលត្រូវធ្វើដំណើរចេញក្រៅភូមិ (ទាំងការធ្វើដំណើរពេលថ្ងៃនិងពេលយប់) ដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 94. តើអ្នកត្រូវមានអ្នកទៅជាមួយទេនៅពេលអ្នកត្រូវធ្វើដំណើរចេញក្រៅផ្ទះឬក្រៅភូមិដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |

| | | | | |
|---|---|---|---|---|
| | | | 95. អ្នកមានសុវត្ថិភាពទេពេលត្រូវធ្វើដំណើរចេញក្រៅភូមិ (ទាំងការធ្វើដំណើរពេលថ្ងៃនិងពេលយប់)ដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| 26 | **ចលនារចំណាកស្រុក** | ដើម្បីវាស់ស្ទង់ចលនាមនុស្សនៅក្នុងគ្រួសារពីកន្លែងមួយទៅកន្លែងមួយទៀត ដោយមានបំណងទៅរស់នៅបណ្ដោះអាសន្នឬជាអចិន្ត្រៃយ៍នៅក្នុងទីតាំងថ្មីនិងផលប៉ះពាល់របស់វាទៅលើសមាជិគ្រួសារដែលនៅសល់។ | 96. តើអ្នក ឬមាននរណាម្នាក់នៅក្នុងផ្ទះរបស់អ្នកត្រូវចាកចេញពីស្រុក/ខេត្ត ឬទៅ ក្រៅប្រទេសដើម្បីធ្វើការដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 97. តើការចំណាកស្រុកជួយអ្នកនិងគ្រួសាររបស់អ្នកមានប្រាក់ចំណូលប្រសើរជាងមុនដែរឬទេ? | បាទ/ចាស =1<br>ទេ =0<br>មិនត្រូវស្ថានភាព=0 |
| | | | 98. តើអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងគ្រួសារដែរឬទេ នៅពេលដែលសមាជិកណាម្នាក់នោះ ចំណាកស្រុក? | បាទ/ចាស =1<br>ទេ =0<br>មិនត្រូវស្ថានភាព=0 |
| | | | 99. នៅពេលមានអាសន្ន, តើសមាជិកគ្រួសាររបស់អ្នកត្រូវបង្ខំចិត្តធ្វើចំណាកស្រុកដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| 27 | **កម្មវិធីរបបសុវត្ថិភាពសង្គម** | ដើម្បីវាស់ស្ទង់កម្មវិធី/ក្រុមនៅក្នុងសហគមន៍ ដែលមានគោលបំណងគាំទ្រពួកគេនិងជួយការពារពួកគេពីភាពងាយរងគ្រោះ។<br>ពាក្យថា របបសុវត្ថិភាពសង្គម សំដៅដល់ ក្រុមសន្សំ ក្រុមជួយខ្លួនឯង, របបឧបត្ថមផ្ដល់ដោយរដ្ឋាភិបាល, ប័ណ្ណក្រីក្រ, ទន់បង្វិល, ធនាគារគោ ធនាគារស្រូវ ជាដើម *etc* | 100. តើអ្នកដឹងថាមានកម្មវិធីរបបសុវត្ថិភាពសង្គម (ក្រុមសន្សំ ក្រុមជួយខ្លួនឯង, របបឧបត្ថមផ្ដល់ដោយរដ្ឋាភិបាល, ប័ណ្ណក្រីក្រ, ទន់បង្វិល, ធនាគារគោ ធនាគារស្រូវ ជាដើម ) ដែរឬទេ, ហើយអ្នកសមាជិក ឬ ទទួលបានរបបពីកម្មវិធីនោះដែរឬទេ? | បាទ/ចាស ហើយខ្ញុំជាផ្នែកមួយនៃកម្មវិធីនេះ = 2<br>បាទ/ចាស មានប៉ុន្តែខ្ញុំបច្ចុប្បន្ននេះមិនមែនជាសមាជិកទេ = 1<br>ទេ មិនមានទេ = 0<br>មិនដឹង = 0 |
| | | | 101. តើមាននរណាម្នាក់ក្នុងគ្រួសាររបស់អ្នក ជាសមាជិក ឬ ទទួលបានរបបពីកម្មវិធីរបបសុវត្ថិភាពសង្គម(ក្រុមសន្សំ | បាទ/ចាស =1<br>ទេ = 0<br>មិនដឹង = 0 |

| | | | | |
|---|---|---|---|---|
| | | | ក្រុមជួយខ្លួនឯង, របបឧបត្ថម្ភផ្តល់ដោយរដ្ឋាភិបាល, ប័ណ្ណក្រីក្រ, ទន់បង្វិល, ធនាគារគោ ធនាគារស្រូវ ជាដើម) ដែរឬទេ? | |
| 28 | **ក្រុមសាសនាផ្សេងៗ** | ដើម្បីវាយតម្លៃថាតើក្រុមសាសនាដើរតួនាទីគាំទ្រឬមិនគាំទ្រ | 102. តើអ្នកយល់ថា ខាងសាសនា បានជួយគាំទ្រដល់តម្រូវការប្រចាំថ្ងៃរបស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 103. តើក្រុមសាសនាជួយអ្នកនៅមុនពេល កំឡុងពេល និងក្រោយពេលដែលជួបប្រទះគ្រោះអាសន្នដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| 29 | ភាពកើនឡើងនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ | ដើម្បីវាយតំលៃថា ប្រសិនបើមានអំពើហឹង្សាលើយេនឌ័រនេះកើតឡើងអាចរាប់បញ្ចូលទាំងការរំលោភបំពានលើរាងកាយ ផ្លូវភេទ សេដ្ឋកិច្ច និងផ្លូវចិត្ត សកម្មភាពទាំង នេះត្រូវបានរាប់បញ្ចូល(ប៉ុន្តែមិនត្រូវបានកំណត់ចំពោះ អំពើហឹង្សាក្នុងគ្រួសារ អំពើហឹង្សាផ្លូវភេទ ការរំលោភ សេពសន្ថវៈការរៀបការដោយបង្ខំរួមមានអាពាហ៍ពិពាហ៍កុមារនិងការប្តូរភេទ | 104. តើអំពើហឹង្សាក្នុងគ្រួសារគឺជាបញ្ហាសម្រាប់ភូមិរបស់អ្នកដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 105. តើមានអាពាហ៍ពិពាហ៍កុមារ(ក្រោមអាយុ18ឆ្នាំ)នៅក្នុងសហគមន៍/ភូមិនេះឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 106. នៅក្នុងភូមិរបស់អ្នក តើអ្នកមានភាពភ័យខ្លាចនៃការចាប់រំលោភសេពសន្ថវៈ ឬការបៀតបៀនផ្លូវភេទដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |
| | | | 107. តើអំពើហឹង្សាយេនឌ័រ (ការរំលោភបំពានផ្លូវភេទ, ការបៀតបៀនផ្លូវភេទតាមរយៈពាក្យសំដី ឬ ផ្លូវអារម្មណ៍, ការរំលោភសេពសន្ថវៈ) មានការកើនឡើងក្នុងកំឡុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ? | បាទ/ចាស = 0<br>ទេ =1 |
| | | | | បាទ/ចាស =1<br>ទេ = 0 |

| | | | | |
|---|---|---|---|---|
| | | | 108. តើអ្នកនឹងហ៊ានរាយការណ៍អំពីករណីអំពើហឹង្សាយេនឌ័រទៅប៉ូលីស / មេភូមិ / អាជ្ញាធរ (ក្រុមប្រឹក្សាឃុំសង្កាត់ទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ) ដែរឬទេ? | |
| 30 | ការត្រៀមខ្លួនជាស្រេចទៅនឹងគ្រោះមហន្តរាយ | ដើម្បីវាស់វែងថាតើអ្នកតបមានអារម្មណ៍ថាបានរៀបចំខ្លួននិងដឹងជាមុននូវអ្វីដែលត្រូវធ្វើក្នុងករណីមានគ្រោះមហន្តរាយ នឹងតើពួកគាត់មានអារម្មណ៍ថាពួកគាត់ជាផ្នែកមួយនៃការរៀបចំផែនការត្រៀមបង្ការគ្រោះមហន្តរាយដែរឬទេ | 109. ប្រសិនបើមានគ្រោះមហន្តរាយកើតឡើងតើគ្រួសាររបស់អ្នកនឹងត្រៀមបង្ការបានមែនទេ? | ប្រាកដណាស់/ពិតណាស់ =3<br>ប្រហែលជាចឹង =2<br>ប្រហែលជាមិនចឹងទេ = 1<br>មិនពិតទាល់តែសោះ = 0 |
| | | | 110. ពេលដែលមានគ្រោះមហន្តរាយកើតឡើង តើអ្នកដឹងថាអ្នកត្រូវធ្វើអ្វីមែនទេ, ហើយបើដឹង តើធ្លាប់បានទទួលការបណ្តុះបណ្តាលពីមុនមកដែរឬទេ? | បាទ/ចាស, ហើយខ្ញុំក៏បានចូលរួមវគ្គបណ្តុះបណ្តាល = 2<br>បាទ/ចាស, ខ្ញុំដឹង =1<br>ទេ = 0 |
| | | | 111. ប្រសិនបើចំបាច់ ក្នុងករណីមានគ្រោះមហន្តរាយកើតឡើង តើគ្រួសាររបស់អ្នកអាចផ្លាស់ប្តូររបៀបរកចំណូល/ជីវភាពរស់នៅដែរឬទេ? | ប្រាកដណាស់/ពិតណាស់ =3<br>ប្រហែលជាចឹង =2<br>ប្រហែលជាមិនចឹងទេ = 1<br>មិនពិតទាល់តែសោះ = 0 |
| | | | 112. ប្រសិនបើមានគ្រោះមហន្តរាយកើតឡើងតើគ្រួសាររបស់អ្នកអាចស្តារឡើងវិញដូចដើម ក្នុងរយៈពេលតែ ៦ ខែ បានដែរឬទេ? | ប្រាកដណាស់/ពិតណាស់ =3<br>ប្រហែលជាចឹង =2<br>ប្រហែលជាមិនចឹងទេ = 1<br>មិនពិតទាល់តែសោះ = 0 |
| ផ្នែកស្ថាប័ន | | | | |

| | | | | |
|---|---|---|---|---|
| 31 | ការទទួលបានការសម្រេចចិត្ត | ដើម្បីវាយតម្លៃពីការចូលរួមស្មើភាពគ្នា រវាងបុរស និងស្ត្រី ក្នុងដំណើរការសម្រេចចិត្ត | 113. តើអ្នកចូលរួមសម្រេចចិត្តក្នុងគ្រួសាររបស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 114. តើអ្នកសម្រេចចិត្តក្នុងសហគមន៍ ឬ ភូមិ/ឃុំ/ របស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| 32 | អំណាចនៃភាពស្មើគ្នា និង យុត្តិធម៌ | ដើម្បីវាយតម្លៃ ថាតើមានភាពស្មើគ្នា (ឧ. លទ្ធភាព និងសិទ្ធិក្នុងការប្រើប្រាស់) រវាងបុរស និងស្ត្រី ដើម្បីទទួលបានធនធាន វគ្គបណ្តុះបណ្តាល (ផ្លូវការ និងក្រៅផ្លូវការ ដើម្បីទទួលបានជំនាញ និងចំណេះដឹង) ព័ត៌មាន (ទាំងផ្លូវការ និងក្រៅផ្លូវការ) និងឱកាសនៃភាពជាអ្នកដឹកនាំ (អ្នកដឹកនាំសហគមន៍ ក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយជាដើម) | 115. ទាក់ទងនឹងប្រាក់កាសនៅក្នុងគ្រួសារ តើអ្នកអាចយកមកចាយ ដូចជាប្តី/ប្រពន្ធ/សមាជិកគ្រួសារផ្សេងទៀតដែរឬទេ? | បាទ/ចាស, មានឱកាសស្មើគ្នា = 2<br>ខ្ញុំមានឱកាសខ្លះដែរ = 1<br>ទេ = 0 |
| | | | 116. ទាក់ទងនឹងការបណ្តុះបណ្តាលរៀនសូត្រ តើអ្នកទទួលឱកាសដូចគ្នា ដូចនឹងប្តី/ប្រពន្ធ/សមាជិកគ្រួសារផ្សេងទៀតដែរឬទេ? | បាទ/ចាស, មានឱកាសស្មើគ្នា = 2<br>ខ្ញុំមានឱកាសខ្លះដែរ = 1<br>ទេ = 0 |
| | | | 117. ទាក់ទងនឹងព័ត៌មាន តើអ្នកទទួលបានដូចនឹងប្តី/ប្រពន្ធ/សមាជិកគ្រួសារផ្សេងទៀត? | បាទ/ចាស, មានឱកាសស្មើគ្នា = 2<br>ខ្ញុំមានឱកាសខ្លះដែរ = 1<br>ទេ = 0 |
| | | | 118. ទាក់ទងឱកាសក្នុងភាពជាអ្នកដឹកនាំ (ដូចជាឱកាសធ្វើជាអ្នកដឹកនាំសហគមន៍/ក្រុមប្រឹក្សាឃុំ/សង្កាត់ ឬ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ ...), តើអ្នកមានឱកាស ដូចនឹងប្តី/ប្រពន្ធ/សមាជិកគ្រួសារផ្សេងទៀតដែរឬទេ? | បាទ/ចាស, មានឱកាសស្មើគ្នា = 2<br>ខ្ញុំមានឱកាសខ្លះដែរ = 1<br>ទេ = 0 |
| 33 | **ផែនការគ្រប់គ្រងគ្រោះមហន្តរាយ** | ដើម្បីវាយតម្លៃថាតើ អ្នកឆ្លើយសំនួរបានដឹងពីគណកម្មការគ្រប់គ្រងគ្រោះមហន្តរាយ ឬផែនការ ថាតើមានដំណើរការទេ និងមានអ្វីខ្លះក្នុងការត្រៀមបង្ការទុកមុន | 119. តើអ្នកដឹងថាមានក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ/គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំ/សង្កាត់ដែរឬទេ? | បាទ/ចាស =1<br>ទេ / មិនដឹង = 0 |

| | | | | |
|---|---|---|---|---|
| | | | 120. នៅកម្រិតថ្នាក់ខេត្ត, តើអ្នកមានផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន ដែរឬទេ? | បាទ/ចាស =1<br>ទេ / មិនដឹង = 0 |
| | | | 121. នៅកម្រិតថ្នាក់ឃុំ/សង្កាត់ តើអ្នកដឹងថាមានផែនការគ្រប់គ្រងគ្រោះមហន្តរាយដែរឬទេ? | បាទ/ចាស =1<br>ទេ / មិនដឹង = 0 |
| 34 | **ជំនួយការខាងក្រៅ នៅពេលដែលត្រូវការ** | ដើម្បីវាយតម្លៃថាតើអ្នកតបសម្ភាសន៍ទទួលបានជំនួយដូចជា ថវិកា សំភារៈប្រើប្រាស់ សេវាកម្ម ឬ ជំនួយបន្ទាន់នៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឬជាសកម្មភាព ឆ្លើយតបពីភ្នាក់ងារខាងក្រៅណាមួយ | 122. នៅពេលមានគ្រោះមហន្តរាយ តើអ្នកបានទទួលជំនួយពេលត្រូវការដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 123. តើអ្នកណាខ្លះផ្តល់ជំនួយខាងក្រៅដែរឬទេ? | ប្រភពច្រើនផ្សេងៗ = 4<br>ជំនួយរដ្ឋាភិបាល =3<br>អង្គការមិនមែនរដ្ឋាភិបាល =2<br>ផ្សេងទៀត= 1<br>ខ្ញុំមិនបានទទួលជំនួយដែលខ្ញុំត្រូវការទេ = 0 |
| 35 | អភិបាលកិច្ចប្រកបដោយការគាំពារ | ពិនិត្យរចនាសម្ព័ន្ធនិងសេវាកម្មរបស់រាជរដ្ឋាភិបាល ដែលមានស្រាប់ក្នុងការគាំពារដល់អ្នកតបទាក់ទងទៅនឹងតម្រូវការ ផលប្រយោជន៍ សិទ្ធិ និងសន្តិសុខរបស់ពួកគេ | 124. តើអ្នកបានទៅបោះឆ្នោតតាមការជ្រើសរើសរបស់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 125. តើអ្នកដឹងពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែរឬទេ? | បាទ/ចាស =1<br>ទេ/ មិនដឹង = 0 |
| | | | 126. តើអ្នកមានអារម្មណ៍ថាក្រុមប្រឹក្សាឃុំ/សង្កាត់ស្តាប់អ្នកដែរឬទេ? | បាទ/ចាស =1<br>ទេ = 0 |
| | | | 127.តើអ្នកធ្លាប់ត្រូវបានតម្រូវអោយបង់ប្រាក់( ក្រៅផ្លូវការ ឬលើសពីរង្វតម្រូវ )អោយទៅអង្គាធរ ឬមន្ត្រីសាធារណៈណាម្នាក់ ដើម្បីអោយគេជួយអ្នកធ្វើអ្វីមួយដែរឬទេ? | បាទ/ចាស = 0<br>ទេ =1 |

| | | | | |
|---|---|---|---|---|
| 36 | ការគាំទ្រដល់តួនាទីរបស់សារព័ត៌មាន | ដើម្បីវាយតម្លៃពីតួនាទីអ្នកសារព័ត៌មានក្នុងការគាំទ្រតម្រូវការ ផលប្រយោជន៍ និងសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយធ្វើអោយជះឥទ្ធិពលតាមរយៈវិទ្យុ ទូរទស្សន៍ និង ឫសារព័ត៌មាន ដល់ស្ថានប័នពាក់ព័ន្ធ និងអ្នកដទៃទៀត | 128.តើអ្នកមានអារម្មណ៍ថាអ្នកសារព័ត៌មានអាចជួយដល់អ្នកក្នុងការទាមទារតម្រូវការរបស់អ្នកដែរឬទេ ? | បាទ/ចាស = 2<br>ទេ = 1<br>មិនដឹង = 0 |
| | | | 129. តើអ្នកមានអារម្មណ៍ថាសារពត៌មានបានផ្សព្វផ្សាយអំពីតម្រូវការរបស់អ្នកទៅកាន់អ្នកពាក់ព័ន្ធគ្រប់គ្រាន់ឬនៅ ? | ទេ = 1<br>មិនដឹង = 0 |
| | | | 130. តើអ្នកមានស្ថានភាពដូចខាងក្រោមនេះដែរឬទេ ? | ប័ណ្ណក្រីក្រ =1<br>ពិការភាព =2<br>ស្រលាញ់ភេទដូចគ្នា =3<br>ជនជាតិដើមភាគតិច =4<br>មានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ =5<br>មិនមែនទាំងអស់ = 0<br>មិនអាចសួរដោយសារមានវត្តមានអ្នកដទៃ = 99 |